**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៣២០
ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ១៩៩៨
**សាលដីកា**
លេខ: ១២៨
ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ...............ជាចៅក្រម
៣-លោក .......... ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ................។

**<u>តំណាងមហាអយ្យការ</u>**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្ដឹងសាទុក្ខសាលដីកា ៣៩៣ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៨០ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្ដឹងសាទុក្ខឈ្មោះ ផអភេទ ប្រុស អាយុ ៣២ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើចំការ មានទីលំនៅ ភូមិ ពោធិសាលាទី ១ ឃុំ ព្រែកក្របៅ ស្រុក កងមាស ខេត្ត កំពង់ចាម ។

និង ចុងចម្លើយឈ្មោះ ផឈ ភេទ ប្រុស អាយុ ៦១ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅ ភូមិពោធិសាលា ឃុំ ព្រែកក្របៅ ស្រុក កងមាស ខេត្ត កំពង់ចាម ។

<u>កម្មវត្ថុបណ្ដឹង:</u> ប្ដឹងទាមទារប្រាក់ថ្លៃឆេះអំពៅ ចំនួន ២៣០០ គុម្ព

តាមបណ្ដឹងសាទុក្ខលេខ ៣៨៤ ចុះថ្ងៃទី ១៥ ខែកញ្ញាឆ្នាំ១៩៩៨ របស់ឈ្មោះ **ផអ** ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣២០ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២២ខែមិថុនាឆ្នាំ ១៩៩៦ របស់ដើមចោទឈ្មោះ **ផឈ** ប្ដឹងទាមទារឲ្យឈ្មោះ ផអនិងប្រពន្ធឈ្មោះ ដផសងប្រាក់មកខ្លួន ចំនួន ១.១៥០.០០ រៀល ដោយអាងហេតុថា: កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ១៩៩៦ ឈ្មោះ ផអបានប្រមូលសំរាមនៅក្នុង ចំការអំពៅរបស់ខ្លួន ដុតធ្វើឲ្យរាលដាលឆេះដល់ចំការអំពៅរបស់ខ្លួនបណ្ដាលឲ្យខូចខាតអំពៅចំនួន ២៣០០

គុម្ព ដែលក្នុង១គុម្ពតម្លៃ ៥០០ រៀល ជាអំពៅដែលកំពុងប្រមូលផលសរុបជាប្រាក់ ១.១៥០.០០០ រៀល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥០ "ក" ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ឲ្យឈ្មោះ ផអនិងប្រពន្ធឈ្មោះ ដផសងថ្លៃខូចខាតអំពៅចំនួន ១.១៥០.០០០ រៀល ឲ្យទៅឈ្មោះ ផឈ ជាដើមចោទ ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ។ មាត្រា ១២១-១២៥ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ ស្ដីពីកិច្ចសន្យា ។

៣-នៅពេលសាលក្រមចូលជាស្ថាពរបើឈ្មោះ ផអនិងប្រពន្ធឈ្មោះ ដផមិនព្រមសងប្រាក់ទៅដើមចោទទេតុលាការ និងធ្វើការរឹបអូសយកទ្រព្យសម្បត្តិជាចលនៈវត្ថុ និងអចលនៈវត្ថុរបស់ឈ្មោះ ផអនិងប្រពន្ធឈ្មោះ ដផលក់ឡាយឡុងយកប្រាក់បង់ទៅម្ចាស់បំណុលតាមច្បាប់ ។ក្នុងករណីមានឧបាយកលទុច្ចរិត តុលាការ និងចាប់បង្ខំដាក់គុកដល់រូបកាយឈ្មោះ ផអដើម្បីបង្ខំទារប្រាក់តាមច្បាប់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដី ពន្ធហ្នឹង រង្វាន់ក្រឡាបញ្ជីប្រាក់ចំណាយក្នុងការប្រគល់ដីកាកោះ សរុបចំនួន ៧០០០ រៀល ។ ប្រាក់នេះបានកាត់យកពីដើមចោទ បានបង់រួចហើយ នៅពេលសាលក្រមចូលជាស្ថាពរ តម្រូវឲ្យចុងចម្លើយ បង់សងជួសវិញបង្គាប់ឲ្យបង់ពន្ធសមាមាត្រ១ភាគរយនៃប្រាក់ ចំនួន ១.១៥០.០០០ រៀល ។ប្រាក់នេះតម្រូវឲ្យដើមចោទ បង់ទុកជាមុន ទើបបង្គាប់ឲ្យចុងចម្លើយ បង់សងវិញជាក្រោយ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើភាគីណាមិនសុខចិត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៣០ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ១៩៩៧ របស់ឈ្មោះ ដផប្ដឹងមិនសុខចិត្តនឹងសាលក្រមលេខ ៥០ "ក" ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ១៩៩៧ របស់ឈ្មោះ ដផទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ ៥០ "ក" ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ១៩៩៧ របស់តុលាការចុះបញ្ជីក្ដី និងពន្ធហ្នឹង ២.៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០ រៀល និងអាជ្ញាធរតុលាការ ៥០០០ រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨៤ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ផអប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណារបស់ឈ្មោះ ផអនិងនាង ដផចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០០០ ។

បានឃើញសារណាតប ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ ផឈ បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា:

សាលដីការដ្ឋប្បវេណីលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុជំរះមេត្តាពិនិត្យ និងសម្រេច ។

ក្រឡាបញ្ជីអានសារណា របស់ឈ្មោះ ផអជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ ។

ក្រឡាបញ្ជីអានសារណាតប របស់ឈ្មោះ ផឈ ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់របាយការណ៍សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

បានឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៤ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោក ផអស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ក្នុងរឿងក្តីនេះសាលាឧទ្ធរណ៍បានតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ចាម ដោយអាងហេតុថា តុលាការនេះមុននឹងសម្រេចបានធ្វើការអង្កេត និងលើកសំអាងហេតុ និងភស្តុតាងសព្វគ្រប់ហើយនោះជាការត្រឹមត្រូវហើយ ។

-យល់ឃើញថា សារណា លើកឡើងរបស់ចុងចម្លើយថា អ្នកបង្កឲ្យឆេះអំពៅរបស់ដើមចោទ គឺឈ្មោះ យាយ ម៉ុន ជាអ្នកម៉ៅការផ្តាច់កាប់គាស់អំពៅក្នុងចំការរបស់ខ្លួន ដូច្នេះខ្លួនពុំព្រមសងការខូចខាតនេះទៅដើមចោទទេនោះជាការពុំត្រឹមត្រូវទេពីព្រោះថា ថ្វីបើអ្នកបង្កឲ្យភ្លើងឆេះទទួលស្គាល់កំហុសរបស់ខ្លួន ក៏ដោយក៏ចុងចម្លើយនៅតែមានកាតព្វកិច្ចទទួលខុសត្រូវផ្ទាល់ជាមួយជននោះដែលជាអ្នកធ្វើឲ្យខូចខាតផលប្រយោជន៍ជនដទៃទៀតដោយសារការធ្វេសប្រហែសរបស់ខ្លួន និងជន

នោះដែលតាមមាត្រា ១២១-១២៦ និងមាត្រា ១៣១ នៃក្រិតច្បាប់លេខ ៣៨ ក្រ ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ចុងចម្លើយនៅតែទទួលខុសត្រូវលើសំណងនោះ ហើយខ្លួនមានសិទ្ធិប្តឹងទារសំណងនោះពីកម្មកររបស់ខ្លួនកមវិញ ។

-យល់ឃើញថា នាពេលសវនាការគូភាគីពុំបានចូលខ្លួនទេ ប៉ុន្តែធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនរួចហើយ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះដោយកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-បានឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**<u>ហេតុដូច្នេះ</u>**

វិនិច្ឆ័យ សេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៨៤ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោក ផអ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៩៣ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ១៩៩៨ របស់សាលឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក ផឈ បានបង់ជួសនៅតុលាការកំពូលចំនួន ១៩.០០០ រៀល គឺៈ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ចំនួន ៤.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន ១៥.០០០ រៀ សរុប ១៩.០០០ រៀល ហើយតម្រូវឲ្យចុងចម្លើយសងប្រាក់ចំនួន ១៩.០០០ រៀល នេះទៅដើមចោទវិញ ។

បង្គាប់ឲ្យចុងចម្លើយបង់ពន្ធសមាមាត្រការកំណត់របស់តុលាការខេត្តកំពង់ចាម ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែកក្កាដា ឆ្នាំ ២០០០ ។